

រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១២/

# ការរាយការណ៍អំពីកុមារ៖ គោលការណ៍ណែនាំស្ដីពីក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មាន

## សេចក្ដីផ្ដើម

អ្នកសារព័ត៌មានមានសក្ដានុពលជាអ្នកនាំមុខក្នុងការផ្សព្វផ្សាយអំពីសិទ្ធិមនុស្ស។ អត្ថបទព័ត៌មាន រូបថត និងវីដេអូរបស់ពួកគេអាចដើរតួនាទីជាភ្នែក ត្រចៀក និងសំឡេងរបស់សាធារណជន ក៏ដូចជាអាចជួយជំរុញរដ្ឋាភិបាល អង្គការមិនមែនរដ្ឋាភិបាល និងសហគមន៍ ឲ្យធ្វើការផ្លាស់ប្ដូរដើម្បីធ្វើឲ្យជីវិតកុមារ និងគ្រួសារបានប្រសើរឡើង។

របៀបដែលប្រព័ន្ធផ្សព្វផ្សាយធ្វើសេចក្ដីរាយការណ៍អំពីកុមារអាចមានឥទ្ធិពលលើការយកចិត្តទុកដាក់របស់សង្គមទៅលើយុវជន។ កុមារ និងយុវជនមានសិទ្ធិទទួលបានការគោរពក្នុងនាមជាមនុស្សដូចគេឯង។ ការធានាថាពួកគេអាចនិយាយតំណាងឲ្យខ្លួនឯង និងចែករំលែកក្ដីសង្ឃឹម ភាពភ័យខ្លាច និងជោគជ័យរបស់ខ្លួន ក៏ដូចជាអាចបង្ហាញពីផលប៉ះពាល់ដែលចេញមកពីឥរិយាបទរបស់មនុស្សពេញវ័យមកលើជីវិតពួកគេ គឺជាការដាស់តឿនដល់សាធារណជនអំពីសំឡេងដ៏មានសារៈសំខាន់របស់ពួកគេ។

នៅពេលដែលអត្ថបទព័ត៌មានពុំបានពិចារណា និងផ្ដល់អាទិភាពដល់សិទ្ធិ និងឧត្តមប្រយោជន៍របស់កុមារ ជាពិសេសសេចក្ដីរាយការណ៍អំពីស្ថានភាពងាយរងគ្រោះមួយចំនួន ដូចជាអំពើហិង្សា ការរំលោភបំពាន ការកេងប្រវ័ញ្ច កុមារប្រឈមមុខនឹងច្បាប់ និងស្ថានភាពដែលកុមារនៅតែទទួលការមាក់ងាយ គឺអាចធ្វើឲ្យកុមាររងគ្រោះធ្ងន់ធ្ងរ ដូចជាការរើសអើង ឬការសងសឹកជាដើម។

ដោយសារកត្តានេះអ្នកសារព័ត៌មានគួរប្រាស្រ័យទាក់ទងជាមួយកុមារដោយយកចិត្តទុកដាក់ និងគិតគូរឲ្យបានល្អិតល្អន់។ គោលការណ៍ណែនាំនេះមានគោលបំណងផ្ដល់យោបល់ជាគន្លឹះ និងអនុសាសន៍ដល់អ្នកសារព័ត៌មាន និងប្រព័ន្ធផ្សព្វផ្សាយអំពីវិធីសាស្ត្រក្នុងការធ្វើសេចក្ដីរាយការណ៍អំពីកុមារប្រកបដោយក្រមសីលធម៌។

## អំពីគោលការណ៍ណែនាំ

គោលការណ៍ណែនាំនេះ[១]ត្រូវបានរៀបចំឡើងសម្រាប់អ្នកសារព័ត៌មាន ដែលសរសេរអត្ថបទអំពីបញ្ហាសង្គម និងបញ្ហាផ្សេងទៀតទាក់ទងនឹងកុមារ ព្រមទាំងអ្នកប្រកបវិជ្ជាជីវៈជាមួយកុមារ ក៏ដូចជានិស្សិតសារព័ត៌មានផងដែរ។

អត្ថបទព័ត៌មានដែលប៉ះពាល់ដល់កុមារ មានដូចជាព័ត៌មានអំពីលទ្ធភាពកុមារក្នុងការទទួលបានសិទ្ធិ និងសេវាសង្គមនានា កុមារដែលរស់នៅតាមមណ្ឌលថែទាំ អំពើហិង្សាលើកុមារ កុមារប្រឈមនឹងការរំលោភបំពាន ការមិនអើពើ ការកេងប្រវ័ញ្ច ឬការជួញដូរ កុមាររងគ្រោះដោយសារមេរោគ និងជំងឺអេដស៍ និងកុមារពិការ ។ល។

ឯកសារជំនួយស្មារតីនេះ មានគោលបំណងជួយបង្កើនការយល់ដឹងរបស់អ្នកសារព័ត៌មានអំពីសិទ្ធិកុមារ ជាពិសេសនៅពេលកុមារត្រូវបានរាយការណ៍ក្នុងព័ត៌មាន តាមប្រព័ន្ធផ្សព្វផ្សាយ រួមទាំងចែករំលែកនូវវិធីសាស្ត្រល្អៗក្នុងការសម្ភាសកុមារ ក៏ដូចជាការប្រមូលរឿងរ៉ាវសម្រាប់ផ្សព្វផ្សាយដល់សាធារណជនដោយធានានូវឧត្តមប្រយោជន៍របស់កុមារ និងមិនធ្វើឲ្យកុមារប្រឈមនឹងគ្រោះថ្នាក់ ឬហានិភ័យបន្ថែមឡើយ។

ឯកសារនេះបែងចែកជាផ្នែកសំខាន់ៗ ដូចតទៅ៖

១) ការពិពណ៌នាអំពីកុមារ និងកិច្ចការពារសិទ្ធិកុមារ
២) គោលការណ៍ និងការណែនាំសម្រាប់សម្ភាស និងថតរូបកុមារ
៣) "កុំបង្កគ្រោះថ្នាក់"៖ ការរាយការណ៍ព័ត៌មានអំពីប្រធានបទរសើប (ទាមទារការយកចិត្តទុកដាក់ខ្ពស់)

## អនុសញ្ញាស្តីពីសិទ្ធិកុមារ

អនុសញ្ញាសហប្រជាជាតិស្តីពីសិទ្ធិកុមារ ចែងពីការងាររបស់រដ្ឋាភិបាល និងបុគ្គលម្នាក់ៗគួរធ្វើ ដើម្បីលើកកម្ពស់ និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិកុមារ។ ប្រទេសកម្ពុជាជាហត្ថលេខីនៃអនុសញ្ញានេះ ដែលត្រូវបានអនុម័តដោយមហាសន្និបាតអង្គការសហប្រជាជាតិ កាលពីថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ១៩៨៩។ ខាងក្រោមគឺជាឧទាហរណ៍មួយចំនួនបង្ហាញពីសិទ្ធិចែងក្នុងអនុសញ្ញាស្តីពីសិទ្ធិកុមារ ដែលមានទំនាក់ទំនងជាមួយនឹងប្រព័ន្ធផ្សព្វផ្សាយ៖

- មាត្រា ១២៖ សិទ្ធិកុមារក្នុងការបញ្ចេញមតិដោយសេរីទៅលើគ្រប់បញ្ហាទាំងអស់ដែលប៉ះពាល់ពួកគេ។
- មាត្រា ១៣៖ កុមារមានសិទ្ធិទទួលបាន និងដឹងព័ត៌មាន រួមទាំងបញ្ចេញមតិរបស់ខ្លួន លើកលែងតែក្នុងករណីសិទ្ធិនេះប៉ះពាល់ដល់សិទ្ធិអ្នកដទៃ។
- មាត្រា ១៦៖ ទទួលបានកិច្ចការពារពីការជ្រៀតជ្រែក ឬការវាយប្រហារ លើភាពជាឯកជន គ្រួសារ ផ្ទះសម្បែង ឬទំនាក់ទំនង កិត្តិយស ឬកេរ្តិ៍ឈ្មោះ។
- មាត្រា ១៧៖ ការទទួលស្គាល់ពីសារៈសំខាន់នៃប្រព័ន្ធផ្សព្វផ្សាយតាមរយៈការលើកទឹកចិត្តឲ្យមានការផ្សព្វផ្សាយព័ត៌មានអំពីអត្ថប្រយោជន៍សម្រាប់កុមារ។

មាត្រាទាំងនេះចែងយ៉ាងច្បាស់ពីសិទ្ធិកុមារដែលគួរទទួលបានកិច្ចការពារពីអ្នកសារព័ត៌មាននៅក្នុងពេលបំពេញការងារប្រចាំថ្ងៃរបស់ខ្លួន។ ប្រព័ន្ធផ្សព្វផ្សាយមានតួនាទីសំខាន់ តាមរយៈការរាយការណ៍ពីភាពអយុត្តិធម៌ដែលកុមារជួបប្រទះ ផ្សព្វផ្សាយឲ្យមានការយល់ដឹងពីបញ្ហានានាដែលប៉ះពាល់កុមារ និងលើកទឹកចិត្តឲ្យមានកិច្ចខិតខំប្រឹងប្រែងជាក់លាក់ ដើម្បីសម្រេចឲ្យបានការផ្លាស់ប្តូរជាវិជ្ជមានពិតប្រាកដដល់ជីវិតកុមារ។



រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៧/ ខួយ បូណា

## ១ ការពិពណ៌នាអំពីកុមារតាមប្រព័ន្ធផ្សព្វផ្សាយ និងកិច្ចការពារសិទ្ធិកុមារ



អ្នកប្រកបវិជ្ជាជីវៈសារព័ត៌មានមានតួនាទីសំខាន់ណាស់ក្នុងការពិពណ៌នាអំពីកុមារថាជាបុគ្គលមានសិទ្ធិ និងទស្សនៈផ្ទាល់ខ្លួន រួមទាំងធានាថាសង្គមបានបំពេញកាតព្វកិច្ចខ្លួនចំពោះកុមារដែលជាប្រជាពលរដ្ឋវ័យក្មេងរបស់ខ្លួន។

ដើម្បីរាយការណ៍ព័ត៌មានឲ្យបានត្រឹមត្រូវ អ្នកសារព័ត៌មានត្រូវគោរពទស្សនៈកុមារ និងពិចារណាដោយប្រុងប្រយ័ត្នចំពោះការសម្រេចចិត្តរបស់ខ្លួនដែលអាចប៉ះពាល់ដល់កុមារ។ អាទិភាពសំខាន់ជាងគេរបស់អ្នកសារព័ត៌មានគួរជាការធានាមិនឲ្យកុមារទទួលរងគ្រោះពីការរាយការណ៍ព័ត៌មានរបស់ខ្លួន។ សូមអានបន្ថែមក្នុងប្រធានបទ "កុំបង្កគ្រោះថ្នាក់" នៅផ្នែកទី៣នៃឯកសារនេះ។

ប្រព័ន្ធផ្សព្វផ្សាយគួរចាត់ទុកកុមារ ជាសមាជិកស្មើភាពនឹងសមាជិកដទៃទៀតក្នុងសង្គម មិនមែនជាមនុស្សក្នុងអនុក្រម ដែលពុំមានសិទ្ធិអំណាចនោះឡើយ។ ដូចគ្នានឹងមនុស្សពេញវ័យដែរ កុមារ និងក្មេងជំទង់ មានសិទ្ធិការតស៊ូ ក្តីសង្ឃឹម សុបិន និងរឿងរ៉ាវដែលពួកគេចង់ប្រាប់ទៅអ្នកដទៃ។ ការពិពណ៌នាអំពីកុមារថាគ្រាន់តែជាជនរងគ្រោះ ឬ វត្ថុ "ជាទីស្រឡាញ់" របស់មនុស្សពេញវ័យបង្កឲ្យមានការយល់ខុសថាទស្សនៈ និងបទពិសោធរបស់កុមារគឺមិនសូវមានតម្លៃ។ ប្រព័ន្ធផ្សព្វផ្សាយមានកាតព្វកិច្ចរាយការណ៍ព័ត៌មានអំពីទស្សនៈនិងបទពិសោធនៃកុមារភាពដោយមិនលំអៀង ស្មោះត្រង់ និងសុក្រឹត ។

គ្រោះថ្នាក់ដែលអាចកើតមានដល់កុមារ ដែលប្រព័ន្ធផ្សព្វផ្សាយគួរត្រូវពិចារណាផងដែរនោះគឺការមើលឃើញ និងទទួលបាននូវប្រភេទព័ត៌មានមួយចំនួនរបស់កុមារដែលអាចបង្កជាគ្រោះថ្នាក់ ជាពិសេសនៅក្នុងសម័យកាលដែលមានការជឿនលឿនខ្លាំងនៃការប្រើប្រាស់អ៊ីនធឺណេត និងបណ្តាញសង្គមនៅក្នុងប្រទេសកម្ពុជា។ ឧទាហរណ៍ ប្រព័ន្ធផ្សព្វផ្សាយត្រូវវាយតម្លៃឲ្យបានល្អិតល្អន់អំពីការផ្សព្វផ្សាយខ្លឹមសារណាដែលមានលក្ខណៈហិង្សានិងរូបភាពដែលបង្កឲ្យមានការខឹងសម្បា។ អ្នកសារព័ត៌មានគួរធានាថា កុមារនឹងមិនទទួលការប៉ះពាល់ផ្នែកអារម្មណ៍ ឬប្រឈមនឹងហានិភ័យនានាដោយសារតែភាពងាយស្រួលទទួលបាននូវខ្លឹមសារសារព័ត៌មានទាំងនោះ រាប់បញ្ចូលទាំងរូបភាពបំផុសឲ្យប្រព្រឹត្តអំពើហិង្សា ឬសកម្មភាពផ្លូវភេទមិនសមស្របជាដើម។

ដើម្បីធានាឲ្យមានការយកចិត្តទុកដាក់លើបញ្ហាកុមារដែលពួកគេសមនឹងទទួលបាន អ្នកសារព័ត៌មាន និងអ្នកគ្រប់គ្រងប្រព័ន្ធផ្សព្វផ្សាយត្រូវបានលើកទឹកចិត្តឲ្យធ្វើការងាររួមគ្នា ដើម្បីការពារសិទ្ធិកុមារ តាមរយៈវគ្គបណ្តុះបណ្តាល ឯកសារព័ត៌មាន និងកិច្ចសហការរវាងគ្នាទៅវិញទៅមកក្នុងចំណោមអ្នកប្រកបវិជ្ជាជីវៈសារព័ត៌មាន។ ការរៀបចំគោលការណ៍ណែនាំផ្ទៃក្នុងឲ្យបានច្បាស់លាស់ សម្រាប់ស្ថាប័នសារព័ត៌មាន ហើយអ្នកគ្រប់គ្រងនិងអ្នកសារព័ត៌មានប្តេជ្ញាចិត្តពេញលេញអនុវត្តទៅតាមគោលការណ៍ណែនាំនោះ អាចជួយធានាឲ្យមានការរាយការណ៍ព័ត៌មានអំពីកុមារតាមបែបផែនដែលផ្តល់ការការពារដល់សិទ្ធិ និងតម្រូវការរបស់ពួកគេបាន។

ឧទាហរណ៍នៃគោលការណ៍ណែនាំនេះមានដូចជា គោលការណ៍ណែនាំដែលបានរៀបចំឡើងដោយ សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ) ដែលជាស្ថាប័នជំរុញឲ្យរដ្ឋាភិបាលឲ្យលើកកម្ពស់យុត្តិធម៌សង្គម និងសិទ្ធិសម្រាប់អ្នកសារព័ត៌មាន។ អង្គការនេះបានបញ្ចូលសិទ្ធិកុមារទៅក្នុងក្រមសីលធម៌វិជ្ជាជីវៈរបស់ខ្លួន។

ប្រព័ន្ធផ្សព្វផ្សាយ BBC ក៏បានបង្កើតនូវផ្នែកមួយយ៉ាងលំអិតនៅក្នុងគោលការណ៍ណែនាំរបស់ខ្លួន ផ្តោតលើកុមារ និងយុវជនក្នុងនាមពួកគេជាប្រភពផ្តល់ព័ត៌មាន ដោយសង្កត់ធ្ងន់លើគោលការណ៍ការណែនាំស្តីអំពីកិច្ចការពារសុខុមាលភាពកុមារ ការសុំអនុញ្ញាតពីកុមារ និងឪពុកម្តាយ និងការពន្យល់ពីផលប៉ះពាល់នៃការចូលរួមផ្តល់ព័ត៌មានរបស់កុមារ ដូចជាករណីសម្ភាសកុមារកំពុងប្រឈមមុខនឹងច្បាប់ជាដើម។

ក្នុងប្រទេសកម្ពុជា មជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) ជាអង្គការមិនមែនរដ្ឋាភិបាល ដែលធ្វើការងារលើកកម្ពស់សេរីភាពក្នុងការសម្តែងមតិ និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ បានរៀបចំនូវក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មានកម្ពុជាដោយបញ្ចូលក្រមសីលធម៌ សម្រាប់ការរាយការណ៍ព័ត៌មានអំពីកុមារ ស្ត្រី និងជនពិការ។

យូនីសេហ្វសូមផ្តល់អនុសាសន៍ជូនប្រព័ន្ធផ្សព្វផ្សាយ និងសមាគមន៍សារព័ត៌មាននៅកម្ពុជាឲ្យរៀបចំ និងអនុវត្តនូវគោលការណ៍ណែនាំស្តីពីការរាយការណ៍ព័ត៌មានអំពីកុមារ ដើម្បីឲ្យអ្នកសារព័ត៌មានអាចយកទៅអនុវត្តតាមក្នុងពេលបំពេញភារកិច្ចរបស់ខ្លួន។

## ២ សម្ភាស និងការថតរូបកុមារ



រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៧/ Antoine Raab

ការថ្លឹងថ្លែងរវាងកាតព្វកិច្ចរបស់អ្នកសារព័ត៌មានក្នុងការប្រាប់ការពិត ទៅនឹងភាពចាំបាច់ដើម្បីការពារកុមារ គឺជារឿងពិបាក និងពាក់ព័ន្ធជាមួយបញ្ហាក្រមសីលធម៌។ តើអ្នកសារព័ត៌មានគួរធ្វើអន្តរាគមន៍ដែរឬទេនៅពេលដែលឃើញជីវិតកុមារកំពុងប្រឈមនឹងហានិភ័យ? តើអ្នកសារព័ត៌មានគួរសម្ភាសកុមារដែរឬទេបន្ទាប់ពីពួកគេជួបប្រទះព្រឹត្តិការណ៍ដែលប៉ះទង្គិចផ្លូវចិត្ត? តើក្នុងកាលៈទេសៈបែបណាដែលអ្នកសារព័ត៌មានគួរបង្ហាញ ឬលាក់អត្តសញ្ញាណកុមារ?

នៅពេលធ្វើសេចក្តីរាយការណ៍ព័ត៌មានពាក់ព័ន្ធនឹងកុមារ ឧត្តមប្រយោជន៍កុមារគួរតែជាអាទិភាពខ្ពស់បំផុត ដែលត្រូវយកមកពិចារណា។ អ្នកសារព័ត៌មានត្រូវធានាថាខ្លួនមិនបង្កគ្រោះថ្នាក់ដល់កុមារ ទាំងក្នុងពេលសម្ភាស ក៏ដូចជាផលវិបាកដែលនឹងកើតមានក្រោយពីអត្ថបទព័ត៌មានត្រូវបានផ្សព្វផ្សាយ។ ខាងក្រោមនេះគឺជាសំណួរគោលមួយចំនួន ដែលអ្នកសារព័ត៌មានអាចសួរខ្លួនឯងមុនពេលសម្ភាសកុមារ៖

- តើកិច្ចសម្ភាសជាមួយកុមារ ធ្វើឡើងដោយមានការយល់ព្រមពីកុមារ និងឪពុកម្តាយ ឬអាណាព្យាបាលរបស់ពួកគេដែរឬទេ?
- តើកិច្ចសម្ភាសនេះធ្វើឡើងដោយបានគិតគូរពីកុមារដែរឬទេដូចជាទុកពេលឲ្យបានគ្រប់គ្រាន់ និងធ្វើឡើងក្នុងបរិយាកាសផ្តល់ភាពកក់ក្តៅដល់កុមារ?
- តើមានការគិតគូរ និងការពន្យល់ដល់អ្នកត្រូវគេសម្ភាស អំពីផលវិបាកដែលអាចកើតមាន ចេញពីចម្លើយរបស់កុមារនៅក្នុងរយៈពេលខ្លីឬរយៈពេលវែងដែរឬទេ?
- តើមានការរៀបចំធានាឲ្យមានកិច្ចការពារដល់កុមារ បន្ទាប់ពីផ្សព្វផ្សាយអត្ថបទសារព័ត៌មានដែរឬទេ និងតើមានប្រព័ន្ធគាំទ្រដែរឬទេ ក្នុងករណីកុមារផ្សេងទៀតទាក់ទងមកបណ្ណាធិការ?
- តើកុមារត្រូវបានគេប្រាប់ថាចម្លើយខ្លួនត្រូវយកទៅធ្វើអ្វីដែរឬទេ? ហើយតើពួកគេត្រូវបានអនុញ្ញាតឲ្យឃើញខ្លឹមសារសារព័ត៌មានដែលបានបោះពុម្ពរួចដែរឬទេ?

ព័ត៌មានពិតភាគច្រើនអាចទទួលបាននៅពេលកុមារកំពុងស្ថិតនៅក្នុងមជ្ឈដ្ឋានជាមួយមិត្តភក្តិ ហើយកត្តានេះសំខាន់ណាស់ដែលអ្នកសារព័ត៌មានត្រូវសុំការយល់ព្រមពីមនុស្សពេញវ័យដែលមានតួនាទីសមស្រប (ដូចជាពុកម្តាយ ឬអាណាព្យាបាលជាដើម) និងត្រូវធានាថាមានមនុស្សពេញវ័យដែលកុមារស្គាល់នៅជិតពួកគេអំឡុងពេលសម្ភាស។

នៅពេលថតរូបកុមារ វាជាការសំខាន់ណាស់ដែលត្រូវចាំថាការបង្ហាញអត្តសញ្ញាណកុមារ តាមរយៈរូបថត បើទោះជាមិនបង្ហាញឈ្មោះក៏ដោយ ក៏អាចបង្កឲ្យមានគ្រោះថ្នាក់ខ្លាំងនៅក្នុងកាលៈទេសៈមួយចំនួនដែរ។ ឧទាហរណ៍កុមារដែលជាជនរងគ្រោះដោយសារអំពើហិង្សា និងការរំលោភបំពាន អាចរងគ្រោះបន្ថែមពីជនប្រព្រឹត្តដែលមិនចង់ឲ្យមានសាក្សីនិយាយពីទង្វើរបស់ពួកគេ។ ក្នុងកាលៈទេសៈបែបនេះ ការប្រើប្រាស់រូបភាពកុមារក្នុងប្រព័ន្ធផ្សព្វផ្សាយអាចបង្កឲ្យមានគ្រោះថ្នាក់បន្ថែមទៀតដល់កុមារ។ នៅពេលសម្ភាស ថតវីដេអូ ឬថតរូប និងសរសេរ ឬផ្សព្វផ្សាយព័ត៌មាន ជានិច្ចកាលអ្នកសារព័ត៌មានត្រូវគិតគូរពីផលវិបាកដែលអាចកើតមានចំពោះកុមារ។ ការសួរខ្លួនឯងថា "ចុះបើកុមារនេះជាកូនរបស់ខ្ញុំវិញ"? គឺជាចំណុចផ្តើមដ៏ល្អសម្រាប់អ្នកសារព័ត៌មាន។



រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៧/ ឌុយ ប៊ុណា

# គោលការណ៍របស់យូនីសេហ្វ និងការណែនាំសម្រាប់សម្ភាសកុមារ

យូនីសេហ្វបានរៀបចំគោលការណ៍ខាងក្រោម ដើម្បីគាំទ្រអ្នកសារព័ត៌មាន នៅពេលធ្វើសេចក្តីរាយការណ៍អំពីបញ្ហាដែលប៉ះពាល់កុមារ។ គោលការណ៍ទាំងនេះ គឺជាជំនួយបង្ហាញដល់ប្រព័ន្ធផ្សព្វផ្សាយ ក្នុងការរាយការណ៍ព័ត៌មានអំពីកុមារតាមបែបផែនដែលសមស្របទៅនឹងអាយុកុមារ និងគិតគូរពីផលវិបាកដែលកុមារអាចជួបប្រទះ និងសម្រាប់គាំទ្រដល់អ្នកសារព័ត៌មានទាំងឡាយណាដែលមានបំណងល្អបំផុតក្នុងការគោរពតាមក្រមសីលធម៌ ដោយបម្រើផលប្រយោជន៍សាធារណៈ និងមិនធ្វើឲ្យប៉ះពាល់ដល់សិទ្ធិកុមារ។

## គោលការណ៍យូនីសេហ្វ

១. សេចក្តីថ្លៃថ្នូរ និងសិទ្ធិកុមារគ្រប់រូបត្រូវបានគោរពក្នុងគ្រប់កាលៈទេសៈទាំងអស់។

២. ក្នុងពេលសម្ភាស និងធ្វើសេចក្តីរាយការណ៍អំពីកុមារ ចាំបាច់ត្រូវយកចិត្តទុកដាក់ពិសេសចំពោះសិទ្ធិកុមារម្នាក់ៗ ក្នុងការទទួលបានភាពជាឯកជន និងការរក្សាការសម្ងាត់ ការស្តាប់យកគំនិតយោបល់ពួកគេ ការផ្តល់ឱកាសឲ្យកុមារចូលរួមសម្រេចចិត្តលើបញ្ហាដែលផលប៉ះពាល់ពួកគេ និងការទទួលបានកិច្ចការពារពីគ្រោះថ្នាក់ និងការសងសឹក រាប់បញ្ចូលទាំងលទ្ធភាពនៃគ្រោះថ្នាក់ និងការសងសឹកដែលអាចកើតឡើងនាពេលអនាគត។

៣. ឧត្តមប្រយោជន៍របស់កុមារម្នាក់ៗ ត្រូវទទួលបានការពារជាអាទិភាពលើអាទិភាពដទៃទៀត រាប់បញ្ចូលទាំងការតស៊ូមតិដើម្បីបញ្ហារបស់កុមារ និងការលើកកម្ពស់សិទ្ធិកុមារផងដែរ។

៤. នៅពេលកំណត់ឧត្តមប្រយោជន៍របស់កុមារណាម្នាក់ គួរពិចារណាពីសិទ្ធិរបស់កុមារនោះក្នុងការបញ្ចេញមតិ និងពិចារណាលើសម្តីរបស់ពួកគេដោយយកចិត្តទុកដាក់ខ្ពស់ស្របទៅតាមអាយុ និងភាពចាស់ទុំរបស់ពួកគេ។

៥. ត្រូវពិគ្រោះយោបល់ជាមួយអ្នកដែលនៅកៀកបំផុតទៅនឹងស្ថានភាពរបស់កុមារ និងដែលអាចវាយតម្លៃទៅលើស្ថានភាពរបស់កុមារបានល្អបំផុត ផលវិបាកផ្នែកនយោបាយ សង្គម និងវប្បធម៌ ដែលកើតឡើងដោយសារការរាយការណ៍ព័ត៌មាននានា។

៦. កុំបោះពុម្ពផ្សាយរឿង ឬរូបភាពណាមួយ ដែលអាចធ្វើឲ្យកុមារ បងប្អូន ឬមិត្តភក្តិរបស់កុមារប្រឈមនឹងហានិភ័យ បើទោះបីជាអត្តសញ្ញាណរបស់កុមារត្រូវបានផ្លាស់ប្តូរ ធ្វើឲ្យព្រាលៗមើលមិនច្បាស់ ឬមិនត្រូវបានប្រើប្រាស់យ៉ាងណាក៏ដោយ។

## ការណែនាំសម្រាប់ការសម្ភាសកុមារ

១. កុំបង្កគ្រោះថ្នាក់ដល់កុមារ ចៀសវាងសួរសំណួរ បញ្ចេញឥរិយាបថ ឬផ្តល់យោបល់ ដែលមានលក្ខណៈវិនិច្ឆ័យមិនពិចារណាអំពីគុណតម្លៃវប្បធម៌ ដែលនាំឲ្យកុមារទទួលរងគ្រោះថ្នាក់ ឬធ្វើឲ្យកុមារទទួលរងភាពអាម៉ាស់ ឬធ្វើឲ្យកុមារនឹកឃើញឡើងវិញនូវការឈឺចាប់ និងទុក្ខសោកបង្កដោយព្រឹត្តិការណ៍ភ័យរន្ធត់កន្លងមក។

២. នៅពេលជ្រើសរើសកុមារយកមកសម្ភាស មិនត្រូវរើសអើងដោយសារភេទ ពូជសាសន៍ អាយុ សាសនា ស្ថានភាពកម្រិតវប្បធម៌ សមត្ថភាពកាយសម្បទារបស់កុមារឡើយ។

៣. កុំបំផ្លើសការពិត៖ កុំឲ្យកុមារនិយាយរឿងឬធ្វើសកម្មភាពអ្វីមួយដែលមិនឆ្លុះបញ្ចាំងពីប្រវត្តិផ្ទាល់ខ្លួនរបស់ពួកគេកន្លងមក។

៤. ធានាយ៉ាងណាឲ្យកុមារ ឬអាណាព្យាបាលដឹងថាពួកគេកំពុងនិយាយជាមួយអ្នកសារព័ត៌មាន។ ពន្យល់អំពីគោលបំណងនៃកិច្ចសម្ភាស និងគោលបំណងនៃការប្រើប្រាស់ព័ត៌មានទាំងនេះ។

៥. សុំការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរពីកុមារ និងពីអាណាព្យាបាលនៅរាល់ពេលសម្ភាស ថតវីដេអូ និងថតរូបភាពទាំងអស់។ ការស្នើសុំការអនុញ្ញាតនេះត្រូវធ្វើឡើងក្នុងកាលៈទេសៈដែលធានាថាកុមារ និងអាណាព្យាបាលមិនទទួលរងការបង្ខិតបង្ខំ និងធានាថាពួកគេយល់ថារឿងរ៉ាវថាពួកគេនឹងអាចត្រូវបានគេផ្សព្វផ្សាយក្នុងប្រទេស ឬសកលលោក។ ជាធម្មតាគេអាចធានាបែបនេះបាន ប្រសិនបើការស្នើសុំការអនុញ្ញាតត្រូវបានធ្វើឡើង ដោយប្រើប្រាស់ភាសារបស់កុមារ និងប្រសិនបើការសម្រេចចិត្តត្រូវបានធ្វើឡើងដោយមានការពិគ្រោះយោបល់ជាមួយមនុស្សពេញវ័យណាម្នាក់ដែលកុមារជឿទុកចិត្ត។



រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៥/ Antoine Raab

៦. យកចិត្តទុកដាក់ចំពោះទីកន្លែង និងរបៀបសម្ភាសកុមារ។ កំហិតចំនួនអ្នកសម្ភាស និងអ្នកថតរូប។ ព្យាយាមធានាថា កុមារមានភាពកក់ក្តៅ និងអាចប្រាប់ពីរឿងរ៉ាវរបស់ពួកគេ ដោយពុំមានរងសម្ពាធពីខាងក្រៅ រួមទាំងសម្ពាធពីអ្នកសម្ភាសផងដែរ។ ក្នុងកិច្ចសម្ភាសសម្រាប់ភាពយន្ត វីដេអូ និងវិទ្យុ សូមពិចារណាអំពីជម្រើសរូបភាព និងសំឡេង ដែលអាចបង្ហាញដោយប្រយោលពីកុមារ និងជីវិត ព្រមទាំងរឿងរ៉ាវនានារបស់ពួកគេ។ ធានាថាកុមារនឹងមិនទទួលរងគ្រោះថ្នាក់ ឬផលប៉ះពាល់ជាអវិជ្ជមាន តាមរយៈការបង្ហាញពីផ្ទះ សហគមន៍ ឬទីតាំងទូទៅរបស់ពួកគេឡើយ។

៧. បន្ទាប់ពីសម្ភាសកុមារចប់ ត្រូវសួរថាតើពួកគេមានសំណួរចង់សួរមកអ្នកវិញដែរឬទេ។ សូមរំលឹកកុមារអំពីគោល-បំណងដែលអ្នកនឹងយកអត្ថបទនេះទៅប្រើប្រាស់ និងរៀបចំផ្ញើអត្ថបទនេះទៅឲ្យពួកគេផងដែរ។ សូមសួរកុមារថាពួកគេចង់ដកចំណុចណាចេញ ឬចង់ផ្លាស់ប្តូរឈ្មោះរបស់គេ ឬព័ត៌មានលំអិតផ្សេងទៀតដែរឬទេ។

## ចំណេះដឹងសម្រាប់សម្ភាសកុមារ

សហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ ក្រោមការគាំទ្រពីគណៈកម្មការអឺរ៉ុបបានផ្តល់នូវដំបូន្មានអំពីរបៀបសម្ភាសដែលមានប្រសិទ្ធិភាព រួមទាំងគោរពនូវសិទ្ធិកុមារ៖

១. លើកលែងតែក្នុងកាលៈទេសៈពិសេស កិច្ចសម្ភាសកុមារជានិច្ចកាលគួរធ្វើឡើងដោយមានវត្តមានមនុស្សម្នាក់ទៀតជាអ្នកបំពេញតួនាទីដើម្បីឧត្តមប្រយោជន៍កុមារ និងដើម្បីផ្តល់ការការពារដល់កុមារ និងអាចផ្អាកកិច្ចសម្ភាសប្រសិនចាំបាច់។

២. អ្នកសម្ភាសគួរអង្គុយ ឬឈរត្រឹមកម្ពស់ស្មើនឹងកុមារ និងមិនត្រូវ "និយាយបែបមើលងាយ" ទោះជានិយាយត្រង់ៗក្តី ឬដោយប្រើពាក្យធៀបក្តី។

៣. នៅក្នុងករណីសម្ភាសសម្រាប់វិទ្យុ ឬទូរទស្សន៍ជាការសំខាន់ណាស់ដែលកុមារត្រូវមានអារម្មណ៍សម្រាក និងមិនភ័យខ្លាចម៉ាស៊ីនថត ឬបច្ចេកវិទ្យាដែលប្រើប្រាស់សម្រាប់សម្ភាសឡើយ។ នេះអាចមានន័យថា ក្រុមថតត្រូវចំណាយពេលនៅជិតកុមារ រហូតដល់កុមារលែងផ្តោតអារម្មណ៍លើម៉ាស៊ីនថត និងភ្លើងបំភ្លឺទាំងនេះ។

៤. សំណួរត្រូវសួរដោយផ្ទាល់ទៅកាន់កុមារ ពោលគឺមិនត្រូវសួរទៅមនុស្សពេញវ័យ ហើយមនុស្សពេញវ័យគួរសង្កេតមើលជាជាងធ្វើអន្តរាគមន៍ បើមិនដូច្នោះទេរឿងរ៉ាវដែលអ្នកទទួលបាន គឺជារឿងរ៉ាវរបស់មនុស្សពេញវ័យនោះ មិនមែនជារឿងរ៉ាវរបស់កុមារឡើយ។

៥. អ្នកសម្ភាសគួរប្រើសំឡេងមួយៗ រាក់ទាក់ និងធម្មតា ហើយមិនត្រូវប្រតិកម្មចំពោះអ្វីដែលកុមារលើកឡើង ដោយបង្ហាញពីភាពភ័យរន្ធត់ ឬភ្ញាក់ផ្អើលឡើយ។

៦. សំណួរគួរមានភាពច្បាស់លាស់ ចំចំណុច ហើយមិនគួរសួរបែបជាសំណួរនាំមុខសម្រាប់កុមារឡើយ។ ដំបូងសូមសួរសំណួរបើក (ដើម្បីកុំឲ្យកុមារទទួលរងសម្ពាធឆ្លើយតាមបែបណាមួយ) ហើយបន្ទាប់មកប្រើសំណួរបិទដើម្បីបង្រួមយកព័ត៌មានពិតដែលអ្នកត្រូវបញ្ជាក់។

៧. សំណួរអាចសួរឡើងវិញក្នុងទម្រង់មួយផ្សេងទៀត ដើម្បីផ្ទៀងផ្ទាត់ថាកុមារបានយល់ពីសំណួរ និងបានឆ្លើយច្បាស់លាស់។

៨. វាជាប្រការល្អដែលសួរសំណួរអំពីការពិតចំពោះអ្វីដែលអ្នកណាម្នាក់បាននិយាយនិងធ្វើ ជាជាងសួរអំពីអារម្មណ៍របស់ពួកគេ។ កុមារជារឿយៗនឹងបង្ហាញអារម្មណ៍ពិតរបស់ខ្លួន នៅពេលពួកគេមានអារម្មណ៍កក់ក្តៅជាមួយនឹងកិច្ចសម្ភាស ប៉ុន្តែពួកគេក៏អាចទទួលរងសម្ពាធនៅពេលដែលត្រូវសួរផ្ទាល់អំពីអារម្មណ៍របស់ពួកគេផងដែរ។

៩. នៅពេលដែលអាចធ្វើទៅបាន គួរសួរសំណួរដើម្បីផ្ទៀងផ្ទាត់ចម្លើយដែលបានផ្តល់កន្លងមក (នេះជាការអនុវត្តល្អសម្រាប់កិច្ចសម្ភាសគ្រប់ប្រភេទទាំងអស់)។

១០. ក្នុងករណីសម្ភាសតាមរយៈអ្នកបកប្រែ គួរយកចិត្តទុកដាក់ថាអ្នកបកប្រែពិតជាបកប្រែអ្វីដែលកុមារបាននិយាយពិតប្រាកដ ដោយមិនបានកែសម្រួល ឬសង្ខេបចម្លើយរបស់កុមារឡើយ។

# ៣ “កុំបង្កគ្រោះថ្នាក់”៖ ការរាយការណ៍ព័ត៌មានអំពីប្រធានបទរសើប

កុមារមានសិទ្ធិទទួលបានការការពារពីការជ្រៀតជ្រែកលើភាពជាឯកជន គ្រួសារ ផ្ទះ និងទំនាក់ទំនងនានារបស់ពួកគេ និងទទួលបានការការពារពីការមួលបង្កាច់ (មាត្រា ៦ នៃអនុសញ្ញាស្តីពីសិទ្ធិកុមារ)។

កុមារថែមទាំងមានសិទ្ធិទទួលការការពារពីរាល់ទម្រង់ទាំងអស់នៃការរើសអើង ដែលប៉ះពាល់ជាអវិជ្ជមានដល់គ្រប់ទិដ្ឋភាពទាំងអស់នៃសុខមាលភាពរបស់ពួកគេ (មាត្រា ៣៦)។

អ្នកសារព័ត៌មានត្រូវធានាថា កិច្ចសម្ភាសកុមារ ឬការផ្សព្វផ្សាយរឿងរ៉ាវអ្វីមួយ មិនត្រូវធ្វើឡើងតាមរបៀបដែលបង្កផលប៉ះពាល់ដល់សុវត្ថិភាព និងសុខមាលភាពរបស់កុមារទាំងក្នុងរយៈពេលខ្លី និងរយៈពេលវែងឡើយ។ ការយកចិត្តទុកដាក់ពិសេសត្រូវធ្វើឡើង នៅពេលកុមារស្ថិតក្នុងស្ថានភាពងាយរងគ្រោះ ដើម្បីកុំធ្វើឲ្យពួកគេក្លាយជាជនរងគ្រោះ និងរុញច្រានពួកគេទៅក្នុងហានិភ័យ និងគ្រោះថ្នាក់បន្ថែមទៀត។ សម្រាប់កុមារជីវិតរបស់ពួកគេនៅតែបន្តទៅមុខទៀត ក្រោយពេលអ្នកសារព័ត៌មានចាកចេញទៅ ដូច្នេះអ្នកជំនាញវិជ្ជាជីវៈសារព័ត៌មាន ចាំបាច់ត្រូវគិតពីផលប៉ះពាល់ពីជំនួបនេះជាមួយកុមារនេះ និងការរាយការណ៍ព័ត៌មានអំពីកុមារ ដោយត្រូវធានាយ៉ាងណាមិនឲ្យមានផលប៉ះពាល់ជាអវិជ្ជមានលើកុមារឡើយ។

ឧទាហរណ៍ កុមារដែលជាជនរងគ្រោះពីការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទ អាចទទួលរងការមាក់ងាយ ឬភាពឯកោពីសង្គមពេញមួយជីវិត បន្ទាប់ពីការផ្សព្វផ្សាយរឿងរ៉ាវនោះដោយបង្ហាញឈ្មោះ ឬមុខរបស់កុមារនោះ។ ការចូលរួមនៅក្នុងកិច្ចសម្ភាស ក៏អាចបង្កឲ្យមានការប៉ះទង្គិចផ្លូវចិត្តផងដែរ។ ការយកចិត្តទុកដាក់ពិសេសចំពោះកុមារទាំងនេះ តាមរយៈការសុំការឯកភាពពេញលេញពីកុមារផ្ទាល់ និងពីអាណាព្យាបាលរបស់ពួកគេ មុនពេលចាប់ផ្តើមសម្ភាស ក៏ដូចជាត្រូវធានាឲ្យកុមារ និងសមាជិកគ្រួសារ អាចទទួលបានសេវាដែលចាំបាច់ ដូចជាសេវាផ្តល់ប្រឹក្សាជាដើម និងតាមរយៈការមិនបង្ហាញព័ត៌មានលំអិតនៅក្នុងអត្ថបទរឿងដែលនាំឲ្យគេដឹងពីអត្តសញ្ញាណកុមារ និងសម្គាល់ដឹងថាកុមារជាជនរងគ្រោះ ដោយសារការរំលោភបំពាន ឬ ការកេងប្រវ័ញ្ចអស់មួយជីវិតឡើយ។ ឧទាហរណ៍មួយទៀតអាចជាការបោះពុម្ពឈ្មោះ ឬរូបថតរបស់កុមារដែលត្រូវបានចាប់ខ្លួន ដោយសារបទល្មើសអ្វីមួយ។ នៅក្នុងករណីបែបនេះកុមារអាចត្រូវបានមិត្តភក្តិ គ្រួសារ និងសហគមន៍ចាត់ទុកជាឧក្រិដ្ឋជន។

យូនីសេហ្វបានរៀបចំនូវគោលការណ៍មួយចំនួន ដើម្បីបង្ហាញពីករណីនិងពេលវេលា ដែលអ្នកសារព័ត៌មានត្រូវប្រុងប្រយ័ត្ន និងយកចិត្តទុកដាក់បន្ថែមក្នុងអំឡុងពេលរាយការណ៍ព័ត៌មានអំពីរឿងរ៉ាវ ដែលមានលក្ខណៈរសើបពាក់ព័ន្ធនឹងកុមារ។

*ឧទាហរណ៍បង្ហាញពីរូបថតដែលអត្តសញ្ញាណរបស់កុមារងាយរងគ្រោះត្រូវបានលាក់កំបាំង ដើម្បីការពារពួកគេមិនឲ្យរងគ្រោះថ្នាក់ និងទទួលការមាក់ងាយបន្ថែមទៀត។ នៅក្នុងស្ថានភាពទាំង២នេះ កិច្ចសម្ភាសកុមារត្រូវបានធ្វើឡើងដោយមានវត្តមានអាណាព្យាបាល ឬអ្នកផ្តល់ការថែទាំដែលអាចជឿទុកចិត្តបាន ដោយមានការយល់ព្រមពេញលេញ និងមានការផ្តល់ការអនុញ្ញាតជាលាយល័ក្ខណ៍អក្សរ។*

*រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៥/ Antoine Raab*



*[ក្មេងស្រីអាយុ១៣ឆ្នាំ ដែលរងគ្រោះដោយសារការជួញដូរមនុស្ស អង្គុយជាមួយភ្នាក់ងារសង្គមកិច្ចមកពីអង្គការមិនមែនរដ្ឋាភិបាល ដែលផ្តល់ការគាំពារ និងការគាំទ្រដល់នាង។]*

*រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៥/ Antoine Raab*



*[ក្មេងប្រុសដែលត្រូវបានជួយសង្គ្រោះពីអ្នកជួញដូរមនុស្ស អង្គុយជាមួយម្តាយចិញ្ចឹមក្នុងផ្ទះរបស់ខ្លួន។]*



រូបថត៖ ©យូនីសេហ្វកម្ពុជា/២០១៧/ ខ្ញុំ ប្រាណ

# គោលការណ៍ណែនាំរបស់យូនីសេហ្វស្តីពីការរាយការណ៍ករណីរសើបពាក់ព័ន្ធនឹងកុមារ

១. កុំមាក់ងាយកុមារបន្ថែមទៀត។ ចៀសវាងការបែងចែកប្រភេទ ឬធ្វើការពិពណ៌នាដែលអាចនាំឲ្យកុមារទទួលរងនូវការគុំកួនជាអវិជ្ជមាន រាប់បញ្ចូលទាំងគ្រោះថ្នាក់ផ្លូវកាយ ឬផ្លូវចិត្ត ឬការរំលោភបំពានពេញមួយជីវិត ការរើសអើង ឬការមិនរាប់រកពីសហគមន៍មូលដ្ឋានរបស់ពួកគេ។

២. ជានិច្ចកាលត្រូវផ្លាស់ប្តូរឈ្មោះ និងធ្វើឲ្យរូបភាពព្រាលមើលមិនច្បាស់ចំពោះរូបបង្ហាញអត្តសញ្ញាណកុមារដែលត្រូវបានគេកំណត់ថាជា៖

ក. ជនរងគ្រោះដោយសារការរំលោភបំពាន ឬការកេងប្រវ័ញ្ចផ្លូវភេទ។

ខ. កុមារប្រព្រឹត្តបទរំលោភបំពានផ្លូវកាយ ឬផ្លូវភេទ

គ. កុមារផ្ទុកមេរោគអេដស៍ ឬបានបាត់បង់ជីវិតដោយសារជំងឺអេដស៍ លើកលែងតែកុមារដែលឪពុកម្តាយ ឬអាណាព្យាបាលផ្តល់ការឯកភាពពេញលេញឲ្យបង្ហាញអត្តសញ្ញាណ។

ឃ. កុមារដែលត្រូវបានចោទប្រកាន់ ឬផ្តន្ទាទោសពីបទល្មើសអ្វីមួយ។

៣. នៅក្នុងកាលៈទេសៈមួយចំនួន ដែលកុមារមានហានិភ័យអាចទទួលរងគ្រោះថ្នាក់ ឬការសងសឹក អ្នកសារព័ត៌មានត្រូវផ្លាស់ប្តូរឈ្មោះរបស់កុមារ ឬធ្វើឲ្យព្រាលមើលមិនច្បាស់នូវរូបភាពដែលបង្ហាញពីអត្តសញ្ញាណរបស់កុមារ ដែលត្រូវបានកំណត់អត្តសញ្ញាណថាជា៖

ក. កុមារដែលស្វែងរកសិទ្ធិជ្រកកោនជាជនភៀសខ្លួន ឬជាជនដែលបាត់បង់ទីលំនៅនៅក្នុងប្រទេស។

ខ. កុមារដែលធ្លាប់រងគ្រោះពីអំពើហិង្សា។

គ. កុមារដែលរស់នៅមណ្ឌលថែទាំ។

ឃ. កុមារអនាថារស់នៅតាមចិញ្ចើមផ្លូវ។

៤. នៅក្នុងករណីមួយចំនួន ការប្រើប្រាស់អត្តសញ្ញាណរបស់កុមារ ដូចជាឈ្មោះ និង/ឬរូបភាពដែលគេអាចសម្គាល់កុមារបាន គឺធ្វើឡើងដើម្បីឧត្តមប្រយោជន៍របស់កុមារ។ ប៉ុន្តែនៅពេលដែលមានការប្រើប្រាស់អត្តសញ្ញាណរបស់កុមារក្នុងករណីនេះ កុមារត្រូវតែនៅទទួលបានការការពារពីគ្រោះថ្នាក់នានា និងត្រូវទទួលបានការគាំទ្រនៅក្នុងករណីដែលមានការមាក់ងាយ ឬការសងសឹក។

ឧទាហរណ៍ដែលបង្ហាញពីករណីពិសេសទាំងនោះរួមមាន៖

ក. នៅពេលកុមារផ្តួចផ្តើមទំនាក់ទំនងជាមួយនឹងអ្នកសារព័ត៌មានចង់ប្រើប្រាស់សិទ្ធិសេរីភាពសម្តែងមតិ និងចង់ឲ្យអ្នកដទៃទៀតអាចស្តាប់ឮពីទស្សនៈរបស់ខ្លួន។

ខ. នៅពេលកុមារចូលរួមនៅក្នុងយុទ្ធនាការជាសកម្មជន ឬការកៀងគរចលនាសង្គមដែលកំពុងបន្តធ្វើ ហើយចង់ឲ្យគេដឹងពីអត្តសញ្ញាណរបស់ខ្លួន។

គ. នៅពេលកុមារចូលរួមនៅក្នុងកម្មវិធីចិត្តសង្គម និងទាមទារឲ្យមានការបង្ហាញឈ្មោះ និងអត្តសញ្ញាណរបស់ខ្លួន ដែលជាផ្នែកមួយដែលនាំឲ្យមាន ការអភិវឌ្ឍល្អប្រសើរសម្រាប់ពួកគេ។

៦. សូមធ្វើការផ្ទៀងផ្ទាត់ព័ត៌មាន ដែលទទួលបានជាមួយកុមារផ្សេងទៀត ឬជាមួយមនុស្សពេញវ័យណាម្នាក់ហើយជាការល្អគឺជាមួយកុមារផង និងមនុស្សពេញវ័យផង។

៧. នៅពេលមានចំងល់ថាតើកុមារម្នាក់អាចទទួលរងហានិភ័យដែរឬអត់នោះ អ្នកសារព័ត៌មានត្រូវរាយការណ៍ពីស្ថានភាពរបស់កុមារទូទៅ ជាជាងអំពីកុមារណាម្នាក់ជាក់លាក់ មិនថារឿងនេះមានតម្លៃប៉ុណ្ណានោះទេ។

ប្រព័ន្ធផ្សព្វផ្សាយមានសក្តានុពលធំធេងដោយមានឥទ្ធិពលលើមតិ និងការយល់ឃើញរបស់ប្រជាពលរដ្ឋ។ អត្ថបទរឿងដែលសរសេរដោយអ្នកសារព័ត៌មានអាចជាប្រទីបបំភ្លឺឲ្យគេដឹងពីបញ្ហានានា ដែលអាចនៅតែបន្តលាក់កំបាំង និងកប់ចោលគ្មានអ្នកណាដឹង។ ដូច្នេះវាជាការសំខាន់ណាស់ដែលអ្នកសារព័ត៌មាន និងអ្នកជំនាញផ្សេងទៀតដែលធ្វើការងារជាមួយប្រព័ន្ធផ្សព្វផ្សាយ ក៏ដូចជានិស្សិតសារព័ត៌មាន ត្រូវមានការយល់ដឹងឲ្យបានច្បាស់លាស់ពីក្រមសីលធម៌នៃការរាយការណ៍ព័ត៌មាន និងពីសិទ្ធិកុមារ រួមបញ្ចូលទាំងសិទ្ធិកុមារក្នុងការបញ្ចេញសំឡេងរបស់ពួកគេឲ្យអ្នកដទៃបានស្តាប់ឮ និងសិទ្ធិទទួលបានការការពារពីរាល់ទម្រង់ទាំងអស់នៃគ្រោះថ្នាក់ និងការប្រឆាំងតបតចេញពីការផ្សព្វផ្សាយព័ត៌មានរបស់ប្រព័ន្ធផ្សព្វផ្សាយ។ យើងសង្ឃឹមថាឯកសារខ្លីនេះ នឹងរួមចំណែកបំផុសឲ្យមានការពិភាក្សាយ៉ាងសកម្មក្នុងចំណោមអ្នកជំនាញវិជ្ជាជីវៈសារព័ត៌មានក្នុងប្រទេសកម្ពុជា ដើម្បីឲ្យអ្នកសារព័ត៌មានកាន់តែច្រើនដឹងពីតួនាទីរបស់ខ្លួនក្នុងការផ្តល់ការការពារសិទ្ធិកុមារ ហើយស្ថាប័នប្រព័ន្ធផ្សព្វផ្សាយអាចធ្វើជាគំរូវិជ្ជមាន តាមរយៈការដាក់ចេញ និងអនុវត្តក្រមសីលធម៌ពាក់ព័ន្ធនឹងការរាយការណ៍ព័ត៌មានអំពីកុមារ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័រ៖ https://www.unicef.org/cambodia/

## អំណានបន្ថែម៖

- គោលការណ៍ណែនាំនិពន្ធអត្ថបទព័ត៌មាន៖ កុមារ និងយុវជនជាប្រភពផ្តល់ព័ត៌មាន រៀបចំដោយ BBC http://www.bbc.co.uk/editorialguidelines/guidelines/children-young-people
- គោលការណ៍ណែនាំស្តីពីការរាយការណ៍ព័ត៌មានអំពីកុមារ រៀបចំដោយសហព័ន្ធអ្នកសារព័ត៌មានអន្តរជាតិ (IFJ) http://admin.ifj.org/en/contents/ifj-guidelines-on-children-reporting
- ឯកសារស្តីពីការសម្ភាសកុមារ៖ ឯកសារជំនួយស្មារតីសម្រាប់អ្នកសារព័ត៌មាន និងអ្នកដទៃទៀត រៀបចំដោយអង្គការសង្គ្រោះកុមារ http://www.savethechildren.org.uk/resources/online-library/interviewing-children-guide-journalists-and-others
- ក្រមសីលធម៌សម្រាប់អ្នកសារព័ត៌មានកម្ពុជា រៀបចំដោយមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ (CCIM) http://www.ccimcambodia.org/resources/code-of-ethics
- អនុសញ្ញាស្តីពីសិទ្ធិកុមារជាភាសាអង់គ្លេស http://www.ohchr.org/en/professionalinterest/pages/crc.aspx

---

[១] គោលការណ៍ណែនាំនេះ ត្រូវបានផ្អែកទៅលើខ្លឹមសារនៃឯកសារមួយចំនួនដូចខាងក្រោម៖

- ឯកសារស្តីពី "ប្រព័ន្ធផ្សព្វផ្សាយ និងសិទ្ធិកុមារ" រៀបចំដោយយូនីសេហ្វ ឆ្នាំ២០០៥។ គេហទំព័រ៖ https://www.unicef.org/ceecis/The_Media_and_Children_Rights_2005.pdf
- ឯកសារស្តីពី "សិទ្ធិកុមារ និងវិជ្ជាជីវៈសារព័ត៌មាន៖ ទស្សនៈវិស័យផ្អែកតាមសិទ្ធិ" រៀបចំដោយយូនីសេហ្វ ឆ្នាំ២០០៧។ គេហទំព័រ៖ http://elearning-events.dit.ie/unicef/html/index_1_1.htm
- ឯកសារស្តីពី "កុមារ និងប្រព័ន្ធផ្សព្វផ្សាយ" រៀបចំដោយយូនីសេហ្វ៖ https://www.unicef.org/magic/briefing/childmedia.pdf
- "គោលការណែនាំសម្រាប់អ្នកសារព័ត៌មាន និងអ្នកប្រកបវិជ្ជាជីវៈសារព័ត៌មាន" រៀបចំដោយសហព័ន្ធសារព័ត៌មានអន្តរជាតិ ឆ្នាំ២០០២។ គេហទំព័រ៖ https://www.unicef.org/philippines/intl_journalists_guidelines.pdf

unicef កម្ពុជា | ដើម្បីកុមារគ្រប់រូប

អគារ Exchange Square លេខ១៩&២០ ជាន់ទី៥ ផ្លូវលេខ ១០៦ ភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ប្រអប់សំបុត្រ១៧៦ រាជធានីភ្នំពេញ
ទូរស័ព្ទ៖ (+៨៥៥-២៣) ២៦០ ២០៤ | អ៊ីម៉ែល៖ phnompenh@unicef.org | គេហទំព័រ៖ www.unicef.org.kh

ភ្ជាប់ទំនាក់ទំនងជាមួយយើង៖

facebook.com/unicefcambodia
youtube.com/unicefcambodia
twitter.com/unicefcambodia
@unicefcambodia